# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកំពង់ស្ពឺ**

សាលក្រមព្រហ្មទណ្ឌលេខ ៩១ "ជ"

ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៣

## ក្នុងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកំពង់ស្ពឺ

បានបើកសវនាការជាសាធារណៈនៅសាលាដំបូងខេត្តកំពង់ស្ពឺ នាថ្ងៃទី១០ ខែមករា ឆ្នាំ២០២៣ ដែលមានសមាសភាពដូចតទៅ ៖

### ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះសាលាដំបូងខេត្តកំពង់ស្ពឺ

លោក [redacted] ចៅក្រមប្រឹក្សាជំនុំជម្រះសាលាដំបូងខេត្តកំពង់ស្ពឺ

លោក [redacted] ចៅក្រមប្រឹក្សាជំនុំជម្រះសាលាដំបូងខេត្តកំពង់ស្ពឺ

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ

### ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ស្ពឺ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៨៧២ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២១ ដែលមានជនជាប់ចោទឈ្មោះ [redacted] ចេក ភេទប្រុស កើតឆ្នាំ១៩៨៤ ជនជាតិខ្មែរ មុខរបរកសិករ ទីកន្លែងនៅភូ [redacted] ខេត្តកំពង់ស្ពឺ ទីលំនៅបច្ចុប្បន្នភូមិព្រៃចខ្ពស់ ឃុំយាអង្គ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ បាន (ស) ម្តាយឈ្មោះ ឃុង (ស) ប្រពន្ធឈ្មោះ [redacted] ដា (រ) មានកូនចំនួន ០១នាក់ ទោសពីមុនគ្មាន ។

**ដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ ០៩ ចុះថ្ងៃទី៣ ខែមករា ឆ្នាំ២០២២ ។**

លោក [redacted] ជាមេធាវីការពារសិទ្ធិជនជាប់ចោទឈ្មោះ [redacted] ចេក ។

**ជាប់ចោទពីបទ** **ប៉ុនប៉ងរំលោភសេពសន្ថវៈ** ប្រព្រឹត្តនៅភូមិក្រវៀក ឃុំយាអង្គ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា ២៧ និងមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សួរ** ភេទប្រុស អាយុ៦៦ឆ្នាំ មុខរបរកសិករ ទីកន្លែងកំណើតភូមិត្រពាំងមាន ឃុំក្រាំងធ្នង ស្រុកដង្កោ ខេត្តកណ្តាល អាសយដ្ឋានបច្ចុប្បន្ននៅភូមិក្រវៀក ឃុំយាអង្គ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted] **សុត** (ស) ម្តាយឈ្មោះ [redacted] **សាន** (ស) ប្រពន្ធឈ្មោះ [redacted] **កែវ** (រ) ។

### ការប្រព្រឹត្តរបស់ជនជាប់ចោទ

កាលពីថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២១ វេលាម៉ោង០២ និង៣០នាទី នៅចំណុចភូមិក្រវៀក ឃុំយាអង្គ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ មានករណី **ប៉ុនប៉ងរំលោភសេពសន្ថវៈ** មួយបានកើតឡើងដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] ចេក ភេទប្រុស អាយុ៣៧ឆ្នាំ បានធ្វើសកម្មភាពចូលទៅក្នុងបន្ទប់បើកមុងរបស់ជនរងគ្រោះ

ឈ្មោះ [redacted] ស្រីរ៉ុត ភេទស្រី អាយុ២៦ឆ្នាំ ខណៈពេលដែលជនរងគ្រោះកំពុងតែគេងលក់ រួចប៉ុនប៉ងធ្វើសកម្មភាពរំលោភសេពសន្ថវៈ ប៉ុន្តែជនរងគ្រោះភ្ញាក់ទាន់ក៏ស្រែកភោឡាតែម្តង ។ ក្រោយកើតហេតុឪពុករបស់ជនរងគ្រោះឈ្មោះ [redacted] សួរ បានដាក់ពាក្យបណ្តឹងមកសមត្ថកិច្ច រួចសមត្ថកិច្ចបានកសាងសំណុំរឿងបញ្ជូនមកអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ ដើម្បីចាត់ការតាមនីតិវិធីច្បាប់ ។

-បានឃើញរបាយការណ៍សំយោគលេខ ៨២/២១ រ.ប.ក ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២១ របស់នាយការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ២៩៩ ដកសព ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ ។

-បានឃើញដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ ៣២ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពង់ស្ពឺ ។

-បានឃើញដីកាចាត់តាំងសមាសភាពក្រុមប្រឹក្សាជំនុំជម្រះលេខ ៨៥ ដចជ.រប/២២ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តកំពង់ស្ពឺ ។

## នាពេលសវនាការ

-អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សួរ បានឆ្លើយថា៖ កាលពីថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២១ វេលាម៉ោង០២ និង៣០នាទី ខ្លួនកំពុងដេកនៅក្នុងផ្ទះសំយាបខាងត្បូងបន្ទប់កូនស្រីរបស់ខ្លួនឈ្មោះ [redacted] ស្រីរ៉ុត អាយុ២៦ឆ្នាំ នៅពេលកើតហេតុខ្លួនបានឮសំឡេងកូនស្រីស្រែកហៅខ្លួនថា៖ ពុក ពូចេកចូលបន្ទប់បើកមុងខ្លួន ពេលនោះខ្លួនក៏បានភ្ញាក់ឡើងដើរចូលទៅក្នុងបន្ទប់កូនស្រីក៏បានឃើញឈ្មោះ [redacted] ចេក ភេទប្រុស អាយុ២៧ឆ្នាំ បានរត់ចេញពីបន្ទប់កូនស្រីខ្លួន រួចខ្លួនក៏ទៅប្រាប់ឪពុកម្តាយក្មេកវាឱ្យដឹងរឿងថា អាចេកបានចូលប៉ុនប៉ងរំលោភកូនស្រីខ្លួន ។

-អំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] វឿន បានឆ្លើយថា៖ នៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២១ វេលាម៉ោង ០២ និង៣០នាទី ក្រោយពេលកើតហេតុខ្លួនបានឃើញឈ្មោះ [redacted] សួរ ភេទប្រុស អាយុ៦៨ឆ្នាំ ត្រូវជាឪពុករបស់ឈ្មោះ [redacted] ស្រីរ៉ុត ភេទស្រី អាយុ២៦ឆ្នាំ បានមកប្រាប់ខ្លួនថាឱ្យទៅមើលអាចេកផង ខ្លួនសុំរឿវាបន្តិច រួចខ្លួនក៏សួរគាត់ថា រឿអាចេករឿងអី ឈ្មោះ [redacted] សួរ ក៏បានប្រាប់មកខ្លួនថា អាចេកវាបានមកបើកចូលមុងកូនស្រីរបស់ខ្លួននៅក្នុងផ្ទះ ហើយខ្លួនក៏ឃាត់ថាកុំរឿវាអី យកវាទៅធ្វើតាមច្បាប់ទៅ រួចខ្លួនក៏បានដើរត្រឡប់មកផ្ទះវិញ។

-អំណានចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ស្រីរ៉ុត បានឆ្លើយថា៖ នៅថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោង០៨ និង៤៥នាទី មុនពេលកើតហេតុនៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២១ វេលាម៉ោង០២ និង៣០នាទី ខ្លួនបានដេកលក់នៅក្នុងផ្ទះចំណុចចម្ការស្រូវ ស្ថិតក្នុងភូមិក្រវៀក ឃុំយាអង្គ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ស្រាប់តែមានឈ្មោះ [redacted] ចេក ភេទប្រុស អាយុ២៧ឆ្នាំ ដែលស្នាក់នៅក្បែរផ្ទះខ្លួន រួចឈ្មោះ [redacted] ចេក ក៏បានដើរចូលមកក្នុងបន្ទប់ខ្លួន បើកមុងបម្រុង នឹងចាប់រំលោភសេពសន្ថវៈ មកលើខ្លួន ហើយខ្លួនក៏ភ្ញាក់ដឹងខ្លួនស្រែកប្រាប់ឪពុកខ្លួនថា៖ ឈ្មោះ [redacted] ចេក វាបានមកចូលមុងខ្លួន បម្រុងនឹងចាប់រំលោភខ្លួន បន្ទាប់មកខ្លួនបានស្រែកហៅឪពុករបស់ខ្លួន គាត់បានដើរចូលមកក៏បានហៅឈ្មោះ [redacted] ចេក ឱ្យចេញពីក្នុងមុងរួចក៏យក គាត់ទៅផ្ទះរបស់គាត់ដើម្បីប្រាប់ឪពុកម្តាយក្មេករបស់គាត់។ ហើយពុកខ្លួនក៏សួរទៅឪពុកម្តាយក្មេករបស់ពូចេកថា៖ គិតយ៉ាងមិចបើ អាចេកវាធ្វើបែបនឹងដាក់កូនស្រីខ្លួន។ រួចខ្លួន និងពុកក៏បានដើរមកផ្ទះវិញលុះព្រឹក ថ្ងៃខែឆ្នាំ ដដែលបានទៅដាក់ពាក្យបណ្តឹងទៅសមត្ថកិច្ច ។

**តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានថា** ក្រោយពីបានពិភាក្សាដេញដោលនាពេលសវនាការរួចមកតាមរយៈចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងចម្លើយរបស់ជនរងគ្រោះ ព្រមទាំងចម្លើយរបស់សាក្សី ឃើញថាមានភាពស៊ីសង្វាក់គ្នា ដែលបានបង្ហាញពីចេតនារបស់ជនជាប់ចោទក្នុងការធ្វើសកម្មភាពបើកចូលក្នុងមុងរបស់ជនរងគ្រោះក្នុងគោលបំណងចាប់រំលោភ ប៉ុន្តែត្រូវជនរងគ្រោះដឹងខ្លួនទាន់ ទើបជនជាប់ចោទអាក់ខានទៅវិញដោយកាលៈទេសៈក្រៅឆន្ទៈ ។ ដូច្នេះតំណាងអយ្យការស្នើសុំតម្កល់ការចោទប្រកាន់ទុកនៅដដែល និងស្នើសុំតុលាការពិនិត្យសម្រេចតាមច្បាប់ ។

**មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋានថា** ៖ តាមការសន្និដ្ឋានរបស់សមត្ថកិច្ច និងតាមរយៈចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងចម្លើយរបស់ជនរងគ្រោះឃើញថា កូនក្តីខ្ញុំបាទពិតជាមានចេតនាក្នុងការប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់មែន ។ ដោយហេតុថាកូនក្តីខ្ញុំបាទ ទើបតែប្រព្រឹត្តបទល្មើសជាលើកទី១ និងស្ថានភាពគ្រួសារមានជីវភាពក្រីក្រ ព្រមទាំងមានបន្ទុកចិញ្ចឹមកូនទៀតផងនោះ ខ្ញុំបាទស្នើសុំតុលាការផ្តល់ស្ថានសម្រាលជូនក្តីខ្ញុំបាទផង ។

## សាលាដំបូងខេត្តកំពង់ស្ពឺ

ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

ក្រោយពីបានស្តាប់អំណានចម្លើយរបស់សាក្សី

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់រួចមក

## សំអាងហេតុ

១.ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់ និង ក្រោយពីបានពិភាក្សាដេញដោលនាពេលសវនាការរួចមកឃើញថា ជនជាប់ចោទឈ្មោះ [redacted] ចេក បានអវត្តមាន គ្រប់ដំណាក់កាលនៃនីតិវិធី ដូច្នេះមិនមានចម្លើយ ឬភស្តុតាងផ្សេងណាមួយរបស់ជនជាប់ចោទ បង្ហាញជូនតុលាការដើម្បីពិចារណានោះទេ ។

២.តាមរបាយការណ៍សំយោគលេខ ៨២/២១ រ.ប.ក ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២១ របស់ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានធ្វើការសន្និដ្ឋាន និងវាយតម្លៃ ៖ ឈ្មោះ[redacted] ចេក ពិតជាបានធ្វើសកម្មភាពចូលក្នុងមុងបម្រុងនឹងប៉ុនប៉ងចាប់រំលោភសេពសន្ថវៈទៅលើជនរងគ្រោះឈ្មោះ [redacted] ស្រីវុធ ប្រាកដមែន ។

៣.តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] **ស្រីវុធ** បានឆ្លើយថា ឈ្មោះ [redacted] **ចេក** បានដើរចូលមកក្នុងបន្ទប់ខ្លួនបើកមុងបម្រុងនឹងចាប់រំលោភសេពសន្ថវៈខ្លួន ប៉ុន្តែខ្លួនក៏ភ្ញាក់ដឹងខ្លួនស្រែកប្រាប់ឪពុក ។

៤.តាមរបាយការណ៍សំយោគ ,លទ្ធផលនៃការអង្កេតស៊ើបសួរ ,ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងចម្លើយរបស់ជនរងគ្រោះ ឃើញថាមានភាពស៊ីសង្វាក់គ្នា ដែលអាចឲ្យតុលាការជឿថា ជនជាប់ចោទឈ្មោះ [redacted] ចេក ពិតជាបានធ្វើសកម្មភាពចូលក្នុងមុងបម្រុងចាប់រំលោភសេពសន្ថវៈទៅលើជនរងគ្រោះឈ្មោះ [redacted] ស្រីវុធ ប៉ុន្តែមិនបានសម្រេចដោយសារតែជនរងគ្រោះបានដឹងខ្លួនទាន់ និងបានស្រែកប្រាប់ឪពុក ទើបធ្វើឲ្យជនជាប់ចោទបញ្ឈប់សកម្មភាពទៅវិញដោយកាលៈទេសៈក្រៅឆន្ទៈ ។

៥.តាមមាត្រា ២៧ នៃក្រមព្រហ្មទណ្ឌ បានចែងថា ការប៉ុនប៉ងក្នុងបទឧក្រិដ្ឋ ឬក្នុងករណីដែលបានចែងទុកក្នុងបទមជ្ឈិម អាចផ្តន្ទាទោសបាន កាលណាលក្ខខណ្ឌខាងក្រោមនេះត្រូវបានបំពេញ ៖

-ចារីចាប់ផ្តើមអនុវត្តបទល្មើសមានន័យថា ចារីបានប្រព្រឹត្តអំពើដែលមានគោលបំណងដោយផ្ទាល់ដើម្បីប្រព្រឹត្តបទល្មើស និង

-ចារីមិនបានបញ្ឈប់អំពើរបស់ខ្លួនទៅវិញដោយស្ម័គ្រចិត្ត តែត្រូវបានរាំងស្ទះ ឬអាក់ខាន ដោយឥទ្ធិពលនៃកាលៈទេសៈក្រៅឆន្ទៈរបស់ខ្លួន ។

អំពើត្រៀមបម្រុងដែលពុំមានគោលបំណងដោយផ្ទាល់ ដើម្បីប្រព្រឹត្តបទល្មើសមិនមែនជាការចាប់ផ្តើមអនុវត្តទេ ។

ការប៉ុនប៉ងក្នុងបទលហុ ពុំទទួលការផ្តន្ទាទោសទេ ។

៦.កាលពីថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២១ វេលាម៉ោង០២ និង៣០នាទី នៅចំណុចភូមិក្រវៀក ឃុំយារអង្គ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ជនជាប់ចោទឈ្មោះ [redacted] ចេក ភេទប្រុស អាយុ៣៧ឆ្នាំ បានធ្វើសកម្មភាពចូលទៅក្នុងបន្ទប់បើកមុងរបស់ជនរងគ្រោះឈ្មោះ [redacted] ស្រីវុធ ភេទស្រី អាយុ២៦ឆ្នាំ ក្នុងគោលបំណងរំលោភសេពសន្ថវៈ ប៉ុន្តែមិនបានសម្រេចដោយសារជនរងគ្រោះបានដឹងខ្លួនទាន់ស្រែកប្រាប់ឪពុក ។

៧.តាមអង្គហេតុខាងលើឃើញថា អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ចេក បានឆ្លុះបញ្ចាំងពីចេតនាទុច្ចរិតក្នុងការប្រព្រឹត្តបទល្មើស **ប៉ុនប៉ងរំលោភសេពសន្ថវៈ** តាមមាត្រា ២៧ និងមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ ។

៨.មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ចេក ភេទប្រុស កើតឆ្នាំ១៩៨៤ ពីបទ **ប៉ុនប៉ងរំលោភសេពសន្ថវៈ** ប្រព្រឹត្តនៅភូមិក្រវៀក ឃុំយារអង្គ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា ២៧ និងមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ ។

## ហេតុដូច្នេះសម្រេច

១/.ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] ចេក ភេទប្រុស កើតឆ្នាំ១៩៨៤ ជនជាតិខ្មែរ ដាក់ពន្ធនាគារចំនួន **៥ (ប្រាំ) ឆ្នាំ** ពីបទ **ប៉ុនប៉ងរំលោភសេពសន្ថវៈ** ប្រព្រឹត្តនៅភូមិក្រវៀក ឃុំយារអង្គ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា ២៧ និងមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ ។

២/.ចេញដីកាបង្គាប់ឱ្យចាប់ និងឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] ចេក ភេទប្រុស កើតឆ្នាំ១៩៨៤ តាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៣/.សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១០ ខែមករា ឆ្នាំ២០២៣ និង ប្រកាសជាសាធារណៈនៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៣ កំបាំងជនជាប់ចោទឈ្មោះ [redacted] ចេក និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស្នូរ ។

-សម្រេចបើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ក្រឡាបញ្ជី**

ហត្ថលេខា និងត្រា [redacted]

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

ហត្ថលេខា និងត្រា [redacted]

---

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម។

ថ្ងៃ ពុធ ៤កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦

កំពង់ស្ពឺ,ថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]